# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៤ សសរ

## សេចក្ដីសំរេច

### ស្ដីពី

### ការបង្កើតក្រុមការងារចាត់ចែងការចេញដំណើរពីកម្ពុជា នៃជនជាតិព្រៃភ្នំវៀតណាម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៥/នស/៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីអន្តោប្រវេសន៍
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## <u>សំរេច</u>

<u>ប្រការ ១</u> : ត្រូវបានបង្កើតក្រុមការងារសំរាប់ចាត់ចែងការចេញដំណើរពីកម្ពុជា នៃជនជាតិព្រៃភ្នំវៀត-ណាម ដែលកំពុងស្នាក់នៅបណ្ដោះអាសន្នក្នុងខេត្តរតនគីរី និងខេត្តមណ្ឌលគិរី ដូចមានសមាសភាពខាងក្រោម ៖

១- ឯកឧត្ដម នាយឧត្ដមសេនីយ៍ ហុក ឡងឌី អគ្គស្នងការនគរបាលជាតិ ជាប្រធាន

២- ឯកឧត្ដម ឡុង វិសាលោ អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៣- ឯកឧត្ដម សក់ សេដ្ឋា អគ្គនាយករដ្ឋបាល ក្រសួងមហាផ្ទៃ សមាជិក

៤- ឯកឧត្ដម ខាំ ខឿន អភិបាល ខេត្តរតនគីរី សមាជិក

៥- ឯកឧត្ដម តោ សឿត អភិបាល ខេត្តមណ្ឌលគិរី សមាជិក

<u>ប្រការ ២</u> : ក្រុមការងារនេះមានភារកិច្ចដូចតទៅ :

- ទំនាក់ទំនងជាមួយតំណាងភាគីអាមេរិក និងតំណាងUNHCR ដើម្បីរៀបចំស្រង់ជាបញ្ជីឈ្មោះអ្នកស្ម័គ្រចិត្តទៅរស់នៅសហរដ្ឋអាមេរិក ។
- ទំនាក់ទំនងជាមួយតំណាងភាគីវៀតណាម និងតំណាងUNHCR ដើម្បីរៀបចំស្រង់ជាបញ្ជីឈ្មោះអ្នកស្ម័គ្រចិត្តត្រឡប់ទៅរស់នៅវៀតណាមវិញ ។
- ទំនាក់ទំនងជាមួយតំណាងUNHCR ដើម្បីអោយអង្គការនេះជួយសំរួលជាមួយភាគីអាមេរិក ឬប្រទេសទីពណាផ្សេង អោយយល់ព្រមទទួលយកអ្នកនៅសេសសល់ អោយអស់ពីកម្ពុជា ។
- ចាត់ចែងធ្វើបែបបទ លិខិតស្នាមផ្សេងៗ ពាក់ព័ន្ធដល់ការធ្វើដំណើរចេញពីកម្ពុជារបស់ជនជាតិព្រៃភ្នំវៀតណាមទាំងអស់ ។
- សហការជាមួយតំណាងUNHCR ដើម្បីគិតគូរដោះស្រាយមធ្យោបាយដឹកជញ្ជូន ស្បៀងអាហារ និងកន្លែងស្នាក់នៅបណ្តោះអាសន្នរយៈពេលខ្លី មុននឹងចេញដំណើរទៅសហរដ្ឋអាមេរិក ឬទៅប្រទេសទីព តាមយន្តហោះ ។

**ប្រការ ៣ :** - ក្រុមការងារនេះមានសិទ្ធិចាត់តាំងក្រុមជំនួយការតាមការចាំបាច់ ហើយមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ។

- ក្រុមការងារត្រូវរាយការណ៍ជាប្រចាំពីសកម្មភាពការងាររបស់ខ្លួន ជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ។ ក្នុងករណីមានបញ្ហាស្មុគស្មាញមិនអាចដោះស្រាយបាន ត្រូវសុំយោបល់មកថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងសាមីខ្លួនដូចមានក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ,ថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋាន រដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-គ្រប់សាមីជន
-ឯកសារ ✓